# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ក

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារជួសជុលខួបដោយក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០២ខ្សែ ប្រវែងសរុប ១៧ ០០០ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២០ម ស្ថិតក្នុងឃុំស្រែរនោង ឃុំរនាម ស្រុកត្រាំកក់ និងស្រុកទ្រាំង ខេត្តតាកែវ។

**យោង:** - លិខិតលេខ ១៩១៧សហវ.អថ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩៧៦/១៦ ក.អ.ជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ សម្រាប់ការងារជួសជុលខួបដោយក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០២ខ្សែ ប្រវែងសរុប ១៧ ០០០ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២០ម (ផ្លូវជាតិលេខ៣-ស្រែរនោង ប្រវែង ៩,៣គ.ម និងផ្លូវជាតិលេខ២-វត្តព្រៃផ្ទេរ ប្រវែង ៧,៧គ.ម) ស្ថិតក្នុងឃុំស្រែរនោង ឃុំរនាម ស្រុកត្រាំកក់ និងស្រុកទ្រាំង ខេត្តតាកែវ ក្នុងតម្លៃសរុបចំនួន ១ ១៦៧ ០០០ ០០០រៀល (មួយប៊ីលាន មួយរយហុកសិបប្រាំពីរលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការផ្ទេរបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ក. ទេសរដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

រដ្ឋលេខាធិការ

**ជូ ទិរិទ្ធ**

**ចម្លងជូន:**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តតាកែវ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តតាកែវ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ
- ឯកសារ-កាលប្បវត្តិ